# មនុស្សល្អមានចត្តសប្បុរស/ ការព្យាបាលការប្រើប្រាស់ហួសកម្រិត

## California Overdose Treatment Act (ច្បាប់ផ្នែកការព្យាបាលការប្រើប្រាស់ហួសកម្រិតនៃរដ្ឋ California)

(AB-635 Drug overdose treatment: liability, Amendment to SECTION 1. Section 1714.22 of the Civil Code)

បុគ្គលណាម្នាក់នឹងមិនមានការទទួលខុសត្រូវចំពោះបណ្តឹងរដ្ឋប្បវេណី ឬក៏ដាក់ឱ្យនៅក្រោមឥទ្ធិពលនៃការចោទប្រកាន់ផ្នែកបទឧក្រិដ្ឋឡើយ ចំពោះការធ្វើជាម្ចាស់ ការចែកចាយ ឬការផ្តល់ជូនថ្នាំពេទ្យសម្រាប់ធ្វើឱ្យលែងមានសារធាតុញៀនហួសកម្រិតនៅក្នុងរាងកាយ នៅពេលដែល៖

- បុគ្គលណាម្នាក់ដែលមិនមានអាជ្ញាប័ណ្ណសម្រាប់ផ្តល់ជូនថ្នាំពេទ្យនោះ បានទទួលការបង្ហាត់ ឬក៏ធ្វើកិច្ចការនោះដោយមានការប្រុងប្រយ័ត្នសមរម្យ ក្នុងគោលបំណងល្អ និងមិនទទួលការបង់ប្រាក់។

## Good Samaritan Law (ច្បាប់ផ្នែកមនុស្សល្អមានចិត្តសប្បុរស)

(HEALTH AND SAFETY CODE - HSC, DIVISION 10. UNIFORM CONTROLLED SUBSTANCES ACT (11000-11651); CHAPTER 6. Offenses and Penalties (11350-11392); ARTICLE 4. Miscellaneous Offenses and Provisions (11364-11376.5))

មានច្បាប់ផ្សេងៗជាស្រេចដែលជួយការពារមនុស្សទាំងឡាយពីការត្រូវទទួលខុសត្រូវ ឬក៏ពីការចាប់ឃាត់ខ្លួន នៅពេលដែលពួកគេធ្វើកិច្ចការនោះក្នុងគោលបំណងល្អ និងដោយមានការប្រុងប្រយ័ត្នសមរម្យដើម្បីស្វែងរកជំនួយផ្នែកពេទ្យ ឬដើម្បីផ្តល់ជូនថ្នាំពេទ្យដែលបានទទួលការអនុម័តសម្រាប់ធ្វើឱ្យលែងមានសារធាតុដែលប្រហាក់ប្រហែលទៅនឹងអាភៀន (opioid) ហួសកម្រិតនៅក្នុងរាងកាយ។

ការធ្វើជាម្ចាស់សារធាតុប្រភេទមានការគ្រប់គ្រងតឹងរ៉ឹង ឬឧបករណ៍ផ្សេងៗសម្រាប់ប្រើប្រាស់សារធាតុនោះសម្រាប់ផ្ទាល់ខ្លួន គឺមិនមែនជាបទល្មើសឡើយ នៅពេលដែលអ្នកអនុវត្តចំណុចខាងក្រោមនេះក្នុងគោលបំណងល្អ៖

- ស្វែងរកជំនួយផ្នែកពេទ្យសម្រាប់មនុស្សម្នាក់ផ្សេងទៀតដែលកំពុងមានបញ្ហាប្រើប្រាស់គ្រឿងញៀនហួសកម្រិត ឬ
- ប្រសិនបើអ្នក ឬនរណាម្នាក់ផ្សេងទៀតកំពុងស្ថិតក្រោមឥទ្ធិពលរបស់គ្រឿងញៀន (ស្រវឹង) នៅពេលកំពុងស្វែងរកជំនួយផ្នែកពេទ្យសម្រាប់ការប្រើប្រាស់ហួសកម្រិត។
- មិនបង្កជាឧបសគ្គដល់បុគ្គលិកផ្នែកពេទ្យ ឬមន្ត្រីប៉ូលីសក្នុងការដោះស្រាយជាមួយនឹងការប្រើប្រាស់ហួសកម្រិតនោះ។

SAPC Substance Abuse Prevention and Control

County of Los Angeles Public Health

# ប្រសិនបើអ្នក ឬមនុស្សជាទីស្រឡាញ់ម្នាក់ត្រូវការទទួលការព្យាបាលនោះ សូមទូរស័ព្ទមកកាន់យើងខ្ញុំនៅពេលណាក៏បាន 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍។

**(បណ្តាញទូរស័ព្ទជំនួយផ្តល់សេវាកម្មផ្នែកការព្យាបាលការប្រើប្រាស់សារធាតុញៀន)**

## SUBSTANCE ABUSE SERVICE HELPLINE

24/7

# 1.844.804.7500

**សម្រាប់ព័ត៌មានបន្ថែម៖**

**កម្មវិធីទប់ស្កាត់ និងគ្រប់គ្រងការប្រើប្រាស់សារធាតុញៀន**
របស់នាយកដ្ឋានសុខភាពសាធារណៈ
នៃខោនធី Los Angeles
(County of Los Angeles
Department of Public Health
**SUBSTANCE ABUSE PREVENTION & CONTROL**)

1000 S. Fremont Avenue
Building A-9 East 3rd Floor
**លេខទូរស័ព្ទ៖ 888.742.7900**
**គេហទំព័រ៖ publichealth.lacounty.gov/sapc**

SAPC Substance Abuse Prevention and Control

County of Los Angeles Public Health